**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧០៥៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៤៣៣៤,៦១ ហិកតា នៅស្រុកជ័យសែន និងស្រុកឆែប ខេត្តព្រះវិហារ ពីតំបន់ព្រៃឈើ និងពីដីសម្បទានសេដ្ឋកិច្ច ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០៨៦ គ.គ្រ ដរខ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.**

ត្រូវបានកាត់ដីសរុបទំហំ ៨៣៣៨,៦១ ហិកតា ដែលក្នុងនោះកាត់ចេញ (១) ទំហំ ៦៨,៥៣ ហិកតា ពីគម្រប់ព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និង(២) ទំហំ ១៦៨០.៨៧ ហិកតា ពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ហេង រូយ (ខេមបូឌា) អ៊ិនធើណេសិនណាល ខមភេនី លីមីធីត (៣) ទំហំ ១៦៩១.០៥ ហិកតា ពីក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណាល ខមភេនី លីមីធីត (៤) ទំហំ ៦៧.៣១ហិកតា ពីក្រុមហ៊ុន ឡាន ហ្វេង (ខេមបូឌា) អ៊ិនធើណេសិនណាល ខមភេនី លីមីធីត (៥) ទំហំ ៨២៧.២៥ ហិកតា ពីក្រុមហ៊ុន រូយ ហ្វេង (ខេមបូឌា) អ៊ិនធើណេសិនណាល ខមភេនី លីមីធីត ដើម្បីធ្វើប្រទានកម្មទំហំ ៣៩៤០,១៣ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៣៩៨,៤៨ ហិកតា រក្សាជាដីបម្រុងទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត នៅខេត្តព្រះវិហារ ក្នុងភូមិ ឃុំ ស្រុក ដូចខាងក្រោម៖

**១.១ ភូមិតស៊ូ ឃុំតស៊ូ ស្រុកជ័យសែន៖**

- ផ្ទៃដីទំហំ ៦៨,៥៣ ហិកតា កាត់ចេញពីគម្រប់ព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១២គ្រួសារ
- ផ្ទៃដីទំហំ ៤៥៦,៨៦ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ច ក្រុមហ៊ុន ហេង រូយ (ខេមបូឌា) អ៊ិនធើណេសិនណាល ខមភេនី លីមីធីត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មទំហំ ៤០៩,០៧ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១១៣ គ្រួសារ និងដីទំហំ ៤៧,៨៩ ហិកតារក្សាជាដីបម្រុងទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត។

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) នៃអនុក្រឹត្យនេះ។

១.២ ភូមិសំរោង ឃុំតស៊ូ ស្រុកជ័យសែន៖

- ផ្ទៃដីទំហំ ១២២៣,៥១ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ច ក្រុមហ៊ុន ហេង រូយ (ខេមបូឌា) អ៊ិនធើណេសិនណាល ខមភេនី លីមីធីត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មទំហំ ១០៤៨,១៩ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២០៥ គ្រួសារ និងដីទំហំ ១៧៥,៣២ ហិកតារក្សាជាដីបម្រុងទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត
- ផ្ទៃដីទំហំ ១៦៩១,០៥ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណាល ខមភេនី លីមីធីត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មទំហំ ១៥៩៤,៩០ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២៩៦ គ្រួសារ និងដីទំហំ ៩៦,១៥ ហិកតា រក្សាជាដីបម្រុងទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត
- ផ្ទៃដីទំហំ ៦៧,៣១ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ច ក្រុមហ៊ុន ឡាន ហ្វេង (ខេមបូឌា) អ៊ិនធើណេសិនណាល ខមភេនី លីមីធីត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៤ គ្រួសារ ។

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២) នៃអនុក្រឹត្យនេះ។

១.៣ ភូមិប្រើសក្អក ឃុំម្លូព្រៃពីរ ស្រុកឆែប៖

- ផ្ទៃដីទំហំសរុប ៨២៧,២៥ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ច ក្រុមហ៊ុន រូយ ហ្វេង (ខេមបូឌា) អ៊ិនធើណេសិនណាល ខមភេនី លីមីធីត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្ម ទំហំ ៧៥២,១៣ ហិកតា ជាកម្មសិទ្ធិជូន ប្រជាពលរដ្ឋចំនួន ១១៨ គ្រួសារ និងដីទំហំ ៧៥,១២ហិកតារក្សាជាដីបម្រុងទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត។

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (៣) នៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូន គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ៧៥៨គ្រួសារ នៅស្រុកជ័យសែន និងស្រុកឆែប ខេត្តព្រះវិហារ ស្ថិតក្នុងភូមិ ឃុំ ដូចខាងក្រោម៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១២៥ គ្រួសារ នៅភូមិតស៊ូ ឃុំតស៊ូ ស្រុកជ័យសែន
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៥១៥ គ្រួសារ នៅភូមិសំរោង ឃុំតស៊ូ ស្រុកជ័យសែន
- ប្រទានកម្មជាកម្មសិទ្ធិជូន ប្រជាពលរដ្ឋចំនួន ១១៨ គ្រួសារ នៅភូមិប្រើសក្អក ឃុំម្លូព្រៃពីរ ស្រុកឆែប ។

**មាត្រា ៣ .-**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ចំនួន ៩៧៥ ក្បាលដី ក្នុងនោះផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៧៣៥ គ្រួសារ លើ ៩៧៣ ក្បាលដី កម្មសិទ្ធិរបស់គណបក្សប្រជាជន ០១ ក្បាលដី និងកម្មសិទ្ធិសាធារណៈរបស់រដ្ឋ (ស្នាក់ការនគរបាល) ០១ ក្បាលដី ដែលស្ថិតនៅក្នុងភូមិ ដូចខាងក្រោម ៖

- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ១៣៧ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ១២២ គ្រួសារ នៅភូមិតស៊ូ
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ៦៨៧ ក្បាលដី ជូនប្រជាពលរដ្ឋ ចំនួន ៥០៥ គ្រួសារ កម្មសិទ្ធិរបស់ការគណៈបក្សប្រជាជន ០១ ក្បាលដី និងកម្មសិទ្ធិសាធារណៈរបស់រដ្ឋ (ស្នាក់ការនគរបាល) ០១ ក្បាលដី នៅភូមិសំរោង
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ១៥១ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ១០៨ គ្រួសារ នៅភូមិប្រើសក្អក ។

**មាត្រា ៤.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ [illegible] ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*